UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

## លោក យ៉ាសហ៍ ហ្គាយ តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ចប់ទស្សនកិច្ចផ្លូវការលើកទីបីរបស់លោកមកកម្ពុជា

*ភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៧* - លោក **យ៉ាសហ៍ ហ្គាយ** តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានបំពេញទស្សនកិច្ចជាផ្លូវការលើកទីបីរបស់លោក មកកម្ពុជា ចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៧ ។ គោលបំណងសំខាន់នៃដំណើរទស្សនកិច្ចរបស់លោកតំណាងពិសេស គឺដើម្បីទទួលការឆ្លើយតបចំពោះរបាយការណ៍ចុងក្រោយបំផុតរបស់លោក ដែលនឹងត្រូវដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងដើម្បីស្វែងយល់បន្ថែមទៀតអំពីស្ថានការណ៍សិទ្ធិមនុស្សថ្មីៗនៅក្នុងប្រទេសនេះ ។ ដូច្នេះ លោកសូមវាយតំលៃខ្ពស់ចំពោះឱកាសជួប និងពិភាក្សាជាមួយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៅក្នុងដំណើរទស្សនកិច្ចរបស់លោក ។ ទោះជាយ៉ាងណាក៏ដោយ លោកមានការសោកស្តាយចំពោះ មន្ត្រីជាន់ខ្ពស់ឯទៀតនៃរដ្ឋាភិបាល ដែលលោកសង្ឃឹមថានឹងបានជួប បែរជាមិនជួបទៅវិញ ។ ខណៈពេលនៅក្រុងភ្នំពេញ លោក ហ្គាយ មានការពិភាក្សាប្រកបដោយផ្លែផ្កាជាមួយតំណាងសង្គមស៊ីវិល គណបក្សនយោបាយ គណៈកម្មការជាតិរៀបចំការបោះឆ្នោត ទីភ្នាក់ងារសហប្រជាជាតិ និងសហគមន៍អ្នកការទូតនានា ។

លោកតំណាងពិសេសសំដែងការស្វាគមន៍ចំពោះការអនុម័តនៅពេលដ៏ខ្លីខាងមុខ នូវក្រមនីតិវិធីព្រហ្មទណ្ឌ បន្ទាប់ពីបានចំណាយពេលជាច្រើនឆ្នាំក្នុងការតាក់តែង ។ លោកសង្ឃឹមថាក្រមនេះនឹងអាចជំនះបាននូវបញ្ហាជាច្រើន ដែលបានរាំងស្ទះដល់ប្រព័ន្ធយុត្តិធមិកម្ពុជា ហើយលោកសង្ឃឹមថា រដ្ឋាភិបាលនឹងផ្តល់អាទិភាពចំពោះការអនុវត្តន៏ក្រមនេះ ។

និទណ្ឌភាពចំពោះការរំលោភសិទ្ធិមនុស្ស នៅតែបន្តគំរាមកំហែងដល់នីតិរដ្ឋនៅកម្ពុជា ។ លោកតំណាងពិសេស សូមសំដែងនូវការសោកស្តាយយ៉ាងខ្លាំងម្តងទៀត ចំពោះសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៧ តំកល់ការផ្តន្ទាទោស ប៊ន សំណាង និងសុខ សំអឿន ទោះបីជាមានភស្តុតាងខ្លាំងដែលអាចឱ្យពួកគេរួចទោសក៏ដោយ ។ នៅក្នុងឆ្នាំ២០០៥ ពួកគេត្រូវបានតុលាការក្រុងភ្នំពេញកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ ដោយមានកំហុសនីតិវិធីយ៉ាងធ្ងន់ធ្ងរ ពីបទធ្វើឃាតលោក ជា វិជ្ជា ប្រធានសហជីពកម្មករ ក្នុងខែមករា ឆ្នាំ២០០៤ ។ ការតំណល់ទោសនេះ គឺជាអំពើអយុត្តិធមិមួយធ្ងន់ធ្ងរ ហើយលោកតំណាងពិសេស បានគូសបញ្ជាក់ជាថ្មី នូវការអំពាវនាវរបស់លោកសុំឱ្យមានការស៊ើបអង្កេតទាំងស្រុង មិនលំអៀង និងអាចជឿទុកចិត្តបាន

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cambodia@ohchr.org

លើករណីឃាតកម្មលើលោក ជា វិជ្ជា និងអំពាវនាវឱ្យធ្វើការផ្តន្ទាទោសជនទាំងឡាយដែលទទួលខុសត្រូវក្នុងករណីឃាតកម្មនេះ ។ លោកក៏បានគាំទ្រចំពោះការស្នើសុំឱ្យមានការលើកលែងទោស ប៊ន សំណាង និងសុខ សំអឿន ពីព្រះមហាក្សត្រផងដែរ ។

លោកតំណាងពិសេសកត់សំគាល់ដោយក្តីបារម្ភ អំពីការបន្តធ្វើការវាយប្រហារ និងការបំភិតបំភ័យ លើសមាជិកនៃចលនាកម្មករនៅក្នុងឆ្នាំកន្លងមកនេះ ។ ការដាក់កំហិតធ្ងន់ធ្ងរ ដោយខុសច្បាប់លើសិទ្ធិរបស់ពួកគេក្នុងការប្រជុំ និងក្នុងការអនុវត្តនីការទទួលខុសត្រូវរបស់ពួកគេ ។ លោកមានក្តីរន្ធត់ចំពោះការធ្វើឃាតលោក ហ៊ី វុទ្ធី ប្រធានសហជីពកម្មករ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៧ ។ ករណីនីទណ្ឌភាពមិនត្រូវឱ្យកើតមានទៀតទេ នៅពេលនេះ ។

ទន្ទឹមនឹងការស្វាគមន៍ចំពោះការរីកចំរើនខាងសេដ្ឋកិច្ច លោកព្រមានថា សិទ្ធិមនុស្ស និងសមធម៌ មិនត្រូវយកមកធ្វើការលះបង់ ដើម្បីសំរេចការរីកចំរើននោះទេ ។ នៅពេលដ៏ឆាប់ៗខាងមុខនេះលោកនឹងចេញរបាយការណ៍មួយ ដែលបង្ហាញពីទស្សនវិស័យខាងសិទ្ធិមនុស្ស អំពីសម្បទានដីគោលដៅសេដ្ឋកិច្ច ។ របាយការណ៍នេះ បង្ហាញថា សម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់នាពេលបច្ចុប្បន្ននេះ បានបង្កការលំបាក និងបានបំផ្លាញជីវភាពរស់នៅរបស់ សហគមន៍ជនបទ ដើម្បីការមានបានរបស់មនុស្សមួយចំនួនតូច ដែលមានទំនាក់ទំនងជាមួយស្ថាប័ននយោបាយ ។ លោកមានកង្វល់ជាខ្លាំងអំពីការបន្តផ្ទេរកម្មសិទ្ធិដីជនជាតិដើមភាគតិច តាមរយៈ "ការចាប់យកដីធ្លី " ដោយខុសច្បាប់ ឬការលក់ដោយបង្ខំ និងការផ្តល់សម្បទានទាំងឡាយ រួមទាំងការផ្តល់អាជ្ញាប័ណ្ណរ៉ែផងដែរ ។

លោកតំណាងពិសេសសង្ឃឹមថានឹងមានការអនុម័តដ៏ឆាប់ៗខាងមុខនេះ នៃវិធានផ្ទៃក្នុងសំរាប់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ហើយលោកស្វាគមន៍ចំពោះការឈានដល់កិច្ចព្រមព្រៀងអំពីបញ្ហាមេធាវីអន្តរជាតិ ។ លោកតំណាងពិសេសមានបំណងគូសបញ្ជាក់អំពីសារសំខាន់នៃការឃ្លាំមើលជាអន្តរជាតិដោយឯករាជ្យចំពោះការកាត់សេចក្តី និងការទទួលខុសត្រូវរបស់អ្នកឃ្លាំមើល ដើម្បីលើកយកបញ្ហាដែលជាកង្វល់ប្រាប់ដល់សាធារណៈជនឱ្យបានដឹង ។ ដើម្បីជាប្រយោជន៍ដល់ការរក្សាសេចក្តីសុចរិត នៃកិច្ចដំណើរការកាត់សេចក្តី លោកគាំទ្រចំពោះការអំពាវនាវឱ្យមានការស៊ើបអង្កេតទាំងស្រុង និងមានតម្លាភាពនៃការចោទប្រកាន់ អំពីការអនុវត្តន៍មិនធម្មតា ក្នុងការជួលបុគ្គលិកឱ្យមកធ្វើការនៅក្នុងអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ។

លោកតំណាងពិសេសសូមធ្វើការកត់សំគាល់ដោយក្តីសោមនស្សថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នៅថ្ងៃទី១ ខែមេសា បានប្រព្រឹត្តទៅក្នុងបរិយាកាសមួយដែលមានអំពើហឹង្សា ការគំរាមកំហែង និងការប្រឈមមុខដាក់គ្នាតិចជាងការបោះឆ្នោតកាលពីពេលកន្លងមក ។ លោកស្វាគមន៍ការធានាអះអាងរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត ថានឹងធ្វើការស៊ើបអង្កេតអំពីមូលហេតុនៃការថយចុះនៃចំនួនអ្នកបោះឆ្នោត និងការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីធានាថា ប្រជាពលរដ្ឋកម្ពុជាទាំងឡាយដែលមានបំណងបោះឆ្នោត នៅក្នុងការបោះឆ្នោតជាតិឆ្នាំក្រោយ នឹងមានឱកាសពេញលេញ ដើម្បីចុះបញ្ជី និងគូសសន្លឹកឆ្នោតរបស់ខ្លួន ហើយថាគណបក្សនយោបាយទាំងអស់ នឹងអាចធ្វើយុទ្ធនាការបោះឆ្នោតប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ។